ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
Ministry of Industry, Mines and Energy

លេខ : ១៥១៥ ឧ.ក.ថ.ជ.រ.ក.រ

ភ្នំពេញ, ថ្ងៃទី២៣ ខែ ធ្នូ ឆ្នាំ២០០៩

# អាជ្ញាប័ណ្ណស្វែងរុករក

## រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ។
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០១/០៩ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ។
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្រ.បក ចុះថ្ងៃទី២៦ ខែមេសា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និង ប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។
- បានឃើញ កិច្ចព្រមព្រៀងស្តីពីការសិក្សាស្រាវជ្រាវ និង ការធ្វើអាជីវកម្មរ៉ែបុកស៊ីត រវាងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ជាមួយក្រុម **អាលុយមីណា (ខេមបូឌា-វៀតណាម) ខូ អិលធីឌី** នៅខេត្តមណ្ឌលគីរី ចុះថ្ងៃទី 23 DEC 2009 ។

## សំរេច

**ប្រការ១ :** អនុញ្ញាតអោយក្រុមហ៊ុន **អាលុយមីណា(ខេមបូឌា-វៀតណាម) ខូ អិលធីឌី** មានអាស័យដ្ឋាន ផ្ទះលេខ ៦១ ផ្លូវលេខ ៣១៥ សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ធ្វើការស្វែងរុករករ៉ែបុកស៊ីត នៅខេត្តមណ្ឌលគីរី លើផ្ទៃដីទំហំ ១២៥៤(មួយពាន់ពីររយហាសិបបួន)គីឡូម៉ែត្រក្រឡា ដែលមានកូអ័រដោណេ ដូចក្នុងឧបសម្ព័ន្ធ ១ ភ្ជាប់មកជាមួយ ។

**ប្រការ២:** ក្រុមហ៊ុន **អាលុយមីណា (ខេមបូឌា-វៀតណាម) ខូ អិលធីឌី** ត្រូវដំណើរការស្វែងរុករកជំរករ៉ែបុកស៊ីត លើផ្ទៃដីដែលបានកំណត់ខាងលើ ដោយអនុវត្តទៅតាមផែនការឆ្នាំ និងកម្មវិធីការងាររបស់ខ្លួនដោយធានាអនុវត្តតាមបទដ្ឋានបច្ចេកទេសក្នុងការសិក្សាស្រាវជ្រាវរុករករ៉ែ ។

**ប្រការ៣:** អាជ្ញាប័ណ្ណនេះមានសុពលភាពរយៈពេល ០២ (ពីរ)ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខា ។ មុនផុតកំណត់ ៣០ថ្ងៃ ក្រុមហ៊ុនត្រូវដាក់ពាក្យសុំអនុញ្ញាតធ្វើការសិក្សាស្រាវជ្រាវរ៉ែបន្តជាថ្មី ។

| Point | X | Y | Point | X | Y |
|---|---|---|---|---|---|
| A 01 | 717000 | 1376000 | A 45 | 760350 | 1373450 |
| A 02 | 725500 | 1376000 | A 46 | 760790 | 1373450 |
| A 03 | 725500 | 1384500 | A 47 | 760790 | 1375520 |
| A 04 | 755000 | 1384500 | A 48 | 761370 | 1375520 |
| A 05 | 755000 | 1383000 | A 49 | 761370 | 1377875 |
| A 06 | 752000 | 1383000 | A 50 | 760775 | 1377875 |
| A 07 | 752000 | 1382000 | A 51 | 760775 | 1380000 |
| A 08 | 750100 | 1382000 | A 52 | 750000 | 1380000 |
| A 09 | 750100 | 1380100 | A 53 | 750000 | 1381500 |
| A 10 | 763000 | 1380100 | A 54 | 745380 | 1381500 |
| A 11 | 763000 | 1379000 | A 55 | 745380 | 1376020 |
| A 12 | 778500 | 1379000 | A 56 | 745060 | 1375700 |
| A 13 | 778500 | 1376500 | A 57 | 742000 | 1375650 |
| A 14 | 777500 | 1376500 | A 58 | 742000 | 1376000 |
| A 15 | 777500 | 1374500 | A 59 | 740550 | 1376000 |
| A 16 | 776500 | 1374500 | A 60 | 740550 | 1377000 |
| A 17 | 776500 | 1366700 | A 61 | 738900 | 1377000 |
| A 18 | 775000 | 1366700 | A 62 | 738900 | 1376000 |
| A 19 | 775000 | 1365700 | A 63 | 737600 | 1376000 |
| A 20 | 773700 | 1365700 | A 64 | 737600 | 1366750 |
| A 21 | 773700 | 1364700 | A 65 | 735900 | 1366750 |
| A 22 | 772000 | 1364700 | A 66 | 735900 | 1364270 |
| A 23 | 772000 | 1363500 | A 67 | 734000 | 1364270 |
| A 24 | 768000 | 1363500 | A 68 | 734000 | 1361430 |
| A 25 | 768000 | 1360500 | A 69 | 735450 | 1361430 |
| A 26 | 765700 | 1360500 | A 70 | 735450 | 1360500 |
| A 27 | 765700 | 1358000 | A 71 | 736450 | 1360500 |
| A 28 | 765000 | 1358000 | A 72 | 736450 | 1358275 |
| A 29 | 765000 | 1355500 | A 73 | 732500 | 1358275 |
| A 30 | 762000 | 1355500 | A 74 | 732500 | 1352700 |
| A 31 | 762000 | 1357000 | A 75 | 728300 | 1352700 |
| A 32 | 761000 | 1357000 | A 76 | 728300 | 1348500 |
| A 33 | 761000 | 1359500 | A 77 | 724000 | 1348500 |
| A 34 | 760000 | 1359500 | A 78 | 724000 | 1344500 |
| A 35 | 760000 | 1361800 | A 79 | 721000 | 1344500 |
| A 36 | 758500 | 1361800 | A 80 | 721000 | 1340000 |
| A 37 | 758500 | 1363500 | A 81 | 717000 | 1340000 |
| A 38 | 756500 | 1363500 | A 82 | 717000 | 1337000 |
| A 39 | 756500 | 1364400 | A 83 | 712000 | 1337000 |
| A 40 | 756000 | 1364400 | A 84 | 712000 | 1335500 |
| A 41 | 756000 | 1365650 | A 85 | 704000 | 1335500 |
| A 42 | 758000 | 1365650 | A 86 | 704000 | 1353000 |
| A 43 | 758000 | 1370700 | A 87 | 717000 | 1353000 |
| A 44 | 760350 | 1370700 | | | |

**ប្រការ៤:** ក្នុងករណីប្រព្រឹត្តល្មើសលើល័ក្ខខ័ណ្ឌនៃកិច្ចព្រមព្រៀងចុះថ្ងៃទី 23 DEC 2009 អាជ្ញាប័ណ្ណនេះនឹងត្រូវដកហូត ឬ ត្រូវពិន័យទៅតាមច្បាប់ស្តីពីការគ្រប់គ្រង និងការធ្វើអាជីវកម្មធនធានរ៉ែ ។

**ប្រការ៥:** អគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានគណនេយ្យ-ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋានរដ្ឋបាល ប្រធានមន្ទីរឧស្សាហកម្ម រ៉ែ និងថាមពល ខេត្តមណ្ឌលគិរី និង ក្រុមហ៊ុន **អាលុយមីណា (ខេមបូឌា-វៀតណាម) ខូ អិលធីឌី** ត្រូវទទួលអនុវត្តអាជ្ញាប័ណ្ណនេះ តាមភារៈកិច្ច រៀងៗខ្លួន ។

**ប្រការ៦:** អាជ្ញាប័ណ្ណនេះមានសុពលភាពអនុវត្តចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

**ចំលងជូន**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់
- ក្រសួងបរិស្ថាន
- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ
- សាលាខេត្តមណ្ឌលគិរី
- ដូចប្រការ៥ "ដើម្បីអនុវត្ត" ✓
- ឯកសារ-កាលប្បវត្តិ

ស៊ុយ_សែម